

# រង្វាន់ការ៉េម

The Asia Foundation - Let’s Read

Sorn Srey Nuch, Sorn Sreynuch

Let’s Read
The Asia Foundation



សីតា និង សាន ចូលចិត្តគូររូបជាមួយជីតារបស់គេណាស់។ ជីតាបានអនុញ្ញាតឱ្យចៅទាំងពីរប្រើប៊ិក និងខ្មៅដៃផាត់ពណ៌ល្អៗដែលគាត់ធ្លាប់ប្រើកាលពីគាត់នៅជាស្ថាបត្យករ។ សីតាយល់ថា ការញ៉ាំការ៉េមបណ្ដើរ គូររូបបណ្ដើរជួយឱ្យនាងមានគំនិតថ្មីៗ និងល្អៗ។ ចំណែកសានវិញយល់ថា ការរក្សាទុកក្រដាសឱ្យស្អាត និងការរៀបខ្មៅដៃឱ្យមានរបៀប ជួយឱ្យគេមានគំនិតថ្មីៗដ៏ល្អបំផុត។



«លោកតា! ខ្ញុំអាចធ្វើអ៊ីចឹងបានពេញមួយថ្ងៃ។» សីតានិយាយជាមួយជីតាបណ្ដើរ យកការ៉េមដែលកំពុងរលាយស្រក់ និងប៊ិកពីរដើម ត្រេះលេងបណ្ដើរ។ ការ៉េមក៏រលាយហូរស្រក់លើក្រដាសរបស់សីតា។ សានសើច ហើយនិយាយថា៖ «ឯងមិនគួរញ៉ាំផងគូររូបផងទេ! មើលចុះ! ការ៉េមឯងស្រក់ដូចជាទឹកស៊ើរ៉ូអ៊ីចឹង មើលទៅគំនូរឯងដូចរូបម៉ាស៊ីនចាហ៊ួយហើយ!»



សីតាចង្អុលទៅគំនូររបស់នាង រួចលាន់មាត់ថា៖ «មិនមែនទេ! វាគឺជារូបខ្លែងយ៉ាងច្បាស់ក្រឡែត!» សានតបវិញថា៖ «ហ្នឹងហើយ! វាជាខ្លែងធ្វើពីស្ករចាហួយ។ តើខ្លែងនោះនឹងអាចហោះបានយ៉ាងម៉េចទៅ? ខ្លែងមែនទែនត្រូវតែដូចខ្លែងដ៏អស្ចារ្យរបស់បងនេះនែ។» សីតាញញឹមចំអកថា៖ «មែនហើយ! ប៉ុន្តែខ្លែងដ៏អស្ចារ្យរបស់បងឯងមើលទៅមិនគួរឱ្យស្រឡាញ់ទាល់តែសោះ។»



ជីតាកាន់កាសែតមួយច្បាប់មក រួចនិយាយថា៖ «ចៅទាំងពីរមើលនែ! ក្រុមហ៊ុនការ៉េមដ៏ធំមួយកំពុងរៀបចំការប្រកួតការរចនាហាងថ្មីរបស់គេ។» សានអានកាសែតឮៗ៖ «ត្រូវការជ្រើសរើសស្ថាបត្យករដែលមិនចាំបាច់មានបទពិសោធ...ដើម្បីរចនាផ្ទៃខាងក្នុង និងខាងក្រៅអគារ...។ ការរចនានោះត្រូវផ្ដោតលើបរិស្ថានជាសំខាន់ ដោយប្រើប្រាស់ការរចនាបែបបៃតង...។ ជាពិសេសតម្រូវឱ្យមានភាពលេចធ្លោ និងពោរពេញដោយគំនិតច្នៃប្រឌិត!» សីតាបន្ថែមថា៖ «ហើយអ្វីដែលសំខាន់បំផុតគឺអ្នកឈ្នះនឹងទទួលបានការ៉េមញ៉ាំរយៈពេលពេញមួយឆ្នាំ។»



ភ្លាមៗនោះ សីតានិងសានចាប់ផ្ដើមគូរគំនូរដែលផុសចេញពីគំនិតរៀងៗខ្លួន។ សីតានឹកគិតពីផ្ទៃខាងក្រៅនៃអគារដែលមានពណ៌ចម្រុះ ហើយមានរូបរាងដូចនំសម្រាប់ដាក់ការ៉េមដោយមានរោយកម្ទេចស្ករ និងផ្លែឈើរីពីលើដំបូល។ សាននឹកគិតពីប្លង់បាតដ៏រឹងមាំដើម្បីអាចផ្ទុកបានមនុស្សច្រើន និងយកឫស្សីទៅក្រាលផ្ទៃបាត។



សីតាសួរជីតាថា៖ «ខ្ញុំនឹងផ្ញើរូបនេះទៅចូលរួមការប្រកួតឥឡូវនេះ ដើម្បីឈ្នះរង្វាន់។ តើលោកតាយល់យ៉ាងណាដែរ?» សានហុចប្លង់បាតរបស់គេទៅជីតាបណ្ដើរ និយាយបណ្ដើរថា៖ «ទេ! ឯងមិនអាចឈ្នះការប្រកួតនេះទេ។ ឯងមើលទៅ! តើឯងអាចចូលក្នុងអគាររបស់ឯងបានដោយរបៀបណា?»



ជីតាពិនិត្យទៅលើការរចនាទាំងពីរយ៉ាងប្រុងប្រយ័ត្ន ដោយប្រើក្រសែភ្នែកដ៏ស្ទាត់ជំនាញរបស់គាត់។



ជីតានិយាយថា៖ «សីតា! ការរចនារបស់ចៅគួរឱ្យទាក់ទាញណាស់ ហើយក្រុមហ៊ុនការ៉េមនឹងពេញចិត្តជាក់ជាមិនខាន។»
«ប៉ុន្តែតាគិតថា អគារនឹងអាចរលំបាក់ ប្រសិនបើគេសង់វានៅផ្នែកខាងចុងនៃនំដាក់ការ៉េមនោះ។»



«សាន! ក្រុមហ៊ុនការ៉េមនឹងសប្បាយចិត្តនៅពេលមានអតិថិជនច្រើន ប៉ុន្តែហាងនោះក៏ត្រូវផ្តល់នូវភាពសប្បាយរីករាយដល់ពួកគេផងដែរ។ ហាងការ៉េមនោះនឹងត្រូវការអគ្គិសនីច្រើនដើម្បីធ្វើឱ្យហាងមានសីតុណ្ហភាពត្រជាក់នៅពេលមានមនុស្សច្រើននៅខាងក្នុងហាង។ ដូច្នេះវាមិនសមស្របនឹងគំនិតដែលចង់ឱ្យមានការរចនាបែបបៃតងនោះឡើយ។» ជីតាបន្ថែមទៀតថា៖ «ស្ថាបត្យករត្រូវអនុវត្តទ្រឹស្តីមួយចំនួនដើម្បីធានាសុវត្ថិភាពដល់មនុស្ស ប៉ុន្តែការរចនាក៏ត្រូវធ្វើឱ្យមនុស្សមានអារម្មណ៍ល្អផងដែរ។»



សីតានិងសានត្រឡប់ទៅកែសម្រួលការរចនារបស់គេឡើងវិញ។ សីតាមិនចង់ផ្លាស់ប្តូរទ្រង់ទ្រាយហាងដែលនាងបានរចនាយ៉ាងស្រស់ស្អាតឡើយ។ ប៉ុន្តែនាងសម្រេចចិត្តយកពែងការ៉េមធ្វើជាទ្រង់ទ្រាយហាងជំនួសឱ្យនំដាក់ការ៉េមវិញ។ នាងក៏បន្ថែមជណ្តើរឡើងមួយនៅច្រកចូល។ ចំណែក សាន មិនចង់ផ្លាស់ប្តូរប្លង់បាតដែលគេបានគិតគូរយ៉ាងល្អិតល្អន់ឡើយ។ ប៉ុន្តែគេសម្រេចថា គេអាចបង្កើតបង្អួចឱ្យបានច្រើនដើម្បីមានខ្យល់ធម្មជាតិចេញចូល ហើយប្តូរកន្លែងសម្រាប់តម្រង់ជួររង់ចាំទៅខាងក្រៅអគារវិញ។ គេនឹងបន្ថែមសំយាបនៅខាងមុខហាងដើម្បីឱ្យមានម្លប់ និងផ្តល់ផាសុកភាពដល់អតិថិជនដែលឈរតម្រង់ជួរ។



សានហុចគំនូរថ្មីរបស់គេទៅជីតា មុនសីតា។ សាននិយាយថា៖ «នេះជាគំនូរជ័យលាភី។ ខ្ញុំទៅយកស្រោមសំបុត្រមកដាក់សិន។»



ជីតាពិនិត្យគំនូរនីមួយៗយ៉ាងល្អិតល្អន់ និងប្រៀបធៀបគ្នាទៅវិញទៅមក។ «អា!» «ហ៊ឹម...!» សីតាលាន់មាត់ថា៖ «សំយាបទ្វារ និងបង្អួច មើលទៅស្អាតម្យ៉ាងដែរ ប៉ុន្តែវានៅតែជាអគារដែលមិនទាក់ទាញទាល់តែសោះ។»



ជីតានិយាយថា៖ «គំនូរទាំងពីរនេះល្អប្រសើរជាងមុនច្រើន និងសុទ្ធតែជាគំនិតល្អៗ។» «ប៉ុន្តែការងាររបស់ស្ថាបត្យករ គឺត្រូវរៀបចំរចនាប្លង់ដែលអតិថិជនចូលចិត្ត និងផ្តល់សុវត្ថិភាពដល់ពួកគេ។» «ផ្នែកនៃគំនូររបស់ចៅទាំងពីរត្រូវនឹងគោលការណ៍ខ្លះហើយ ប៉ុន្តែមិនទាន់មានគំនូរណាដែលត្រូវនឹងគោលការណ៍មួយរយភាគរយទេ!»



សីតាស្រែកឡើងថា៖ «ខ្ញុំគ្រាន់តែចង់បង្ហាញគំនិតដ៏ច្នៃប្រឌិតរបស់ខ្ញុំប៉ុណ្ណោះ!» ចំណែកសានប្រែទឹកមុខក្រហម រួចនិយាយថា៖ «អគារនេះតូចណាស់ មិនអាចដាក់អ្វីៗចូលទេ!» ជីតានិយាយថា៖ «គំនិតរបស់ចៅទាំងពីរប្រៀបបានដូចជាល្បែងផ្គុំរូបអ៊ីចឹងណាចៅ។»



សីតានិងសានអង្គុយដោយស្ងៀមស្ងាត់ រួចសម្លឹងមើលគំនូររបស់គេរៀងខ្លួន។ ទីបំផុត សាននិយាយថា៖ «ប្រសិនបើឯងយកជណ្តើរចេញ ឯងអាចដាក់ទ្វារនៅខាងក្រោមបាន។ នៅពេលនោះ អតិថិជនគ្រប់រូប ទាំងឯង ទាំងខ្ញុំ និងលោកតានឹងអាចចូលទិញការ៉េមបានយ៉ាងងាយស្រួល។» សីតាបន្ថែមថា៖ «ប្រសិនបើបងឯងបន្ថែមបញ្ចួរជាច្រើនដែលមានរាងដូចផ្លែឈើរី ហាងការ៉េមនេះនឹងមើលទៅគួរឱ្យទាក់ទាញ។»



ពួកគេខិតកៅអីជិតគ្នា ហើយនាំគ្នាស្វែងរកវិធីផ្សេងទៀតដើម្បីកែលម្អអគាររបស់គេដោយយកគំនិតពីគ្នាទៅវិញទៅមក។ សានផ្លាស់ប្តូរប្លង់បាតរបស់គេឱ្យមានរាងមូល ដើម្បីឱ្យស៊ីគ្នានឹងពែងការ៉េមដែលសីតាបានគូរ។ ចំណែកសីតាបានគូរអគាររបស់នាងឡើងវិញ ដោយបន្ថែមបង្អួចឱ្យបានច្រើន ឱ្យខ្យល់ចេញចូល និងបន្ថែមសំយាបលើបង្អួចនិងទ្វារ ដែលជាគំនិតរបស់សាន។



មិនយូរប៉ុន្មាន ពួកគេក៏អាចគិតឃើញថា គេអាចដាក់បញ្ចូលគំនិតល្អៗបំផុតរបស់គ្រួសារគ្នាឱ្យក្លាយជាការរចនាដ៏អស្ចារ្យមួយ ដូចល្បែងផ្គុំរូបដែលជីតានិយាយអំពីបាញ់មិញអ៊ីចឹង។



បន្ទាប់ពីការប្រឹងប្រែងជាច្រើនម៉ោង គំនូរជាច្រើនសន្លឹក និងការជជែកវែកញែកមួយចំនួនរួចមក សីតា និងសាន បានហុចរូបគំនូរមួយដែលគេបានរចនារួមគ្នាទៅឱ្យជីតា។ ជីតាពិនិត្យរូបគំនូរអាគារដែលមានពណ៌ចម្រុះនៅផ្ទៃខាងក្រៅ និងប្លង់បាតលម្អិតដែលគិតគូរពីបរិស្ថាននៅផ្ទៃខាងក្នុង។ ជីតានិយាយថា៖ «ក្នុងនាមជាស្ថាបត្យករ ចៅត្រូវរចនារហូតទាល់តែបំពេញតម្រូវការទាំងអស់របស់អតិថិជន និងត្រូវចំណាយពេលយូរ។ ហើយចៅៗបានធ្វើការងាររួមគ្នាដើម្បីសម្រេចបានការរចនាដ៏អស្ចារ្យនេះ!»



សីតានិងសានបត់ប្លង់ដែលគេបានផ្ញើរមគ្នាយ៉ាងប្រុងប្រយ័ត្ន រួចដាក់ចូលក្នុងស្រោមសំបុត្រដើម្បីផ្ញើទៅចូលរួមប្រកួត។ ជីតាសួរថា៖ «តើយើងគួរអបអរសមិទ្ធផលនេះដោយរបៀបណា?» សីតានិងសានស្រែកព្រមគ្នាថា៖ «ទិញការ៉េមថែម!»



Generously supported by Smart Axiata

អនុញ្ញាតឱ្យប្រើប្រាស់ដោយ ក្រសួងអប់រំ យុវជន និងកីឡា

Brought to you by

The Asia Foundation

Let's Read is an initiative of The Asia Foundation's Books for Asia program that fosters young readers in Asia and the Pacific.
booksforasia.org
To read more books like this and get further information about this book, visit letsreadasia.org


**Original Story**

*រង្វាន់ការ៉េម (The Ice Cream Prize)*, Author: The Asia Foundation - Let's Read. Illustrator: Sorn Srey Nuch, Sorn Sreynuch. Published by The Asia Foundation - Let's Read, © The Asia Foundation - Let's Read. Released under CC-BY-NC-4.0.

This work is a modified version of the original story. © The Asia Foundation, 2020. Some rights reserved. Released under CC-BY-NC-4.0.

For full terms of use and attribution, http://creativecommons.org/licenses/by-nc/4.0/